# ជួយពួកគេនៅតាមផ្លូវត្រឡប់ទៅផ្ទះរបស់ពួកគេវិញ

*ប្រធានហិនរី ប៊ី អាវរិង*
*ជាទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយ*

បងប្អូនប្រុសស្រី ព្រះវរបិតាសួគ៌របស់យើងចង់ ហើយត្រូវការយើងឱ្យជួយកូនចៅខាងវិញ្ញាណរបស់ទ្រង់ត្រឡប់ ទៅរកទ្រង់វិញ។ ខ្ញុំនិយាយនៅថ្ងៃនេះទៅកាន់មនុស្សវ័យក្មេង ដែលមានជំនឿលើសាសនាចក្រពិតនេះ ដែលបានចាប់ផ្ដើមដើររួចហើយនៅលើផ្លូវតូចត្រង់ និងចង្អៀត ដើម្បីត្រឡប់ទៅកាន់គេហដ្ឋានសួគ៌ារបស់ពួកគេវិញ។ ទ្រង់ចង់ឱ្យវិញ្ញាណរបស់ពួកគេមានភាពរឹងមាំតាំងពីនៅវ័យក្មេង ដើម្បីឈរនៅលើផ្លូវនោះ។ ហើយទ្រង់ត្រូវការជំនួយ ពីពួកយើង ដើម្បីជួយពួកគេត្រឡប់ទៅកាន់ផ្លូវនោះវិញឱ្យបានឆាប់ ប្រសិនបើពួកគេចាប់ផ្ដើមវង្វេង។

ខ្ញុំចាប់ផ្ដើមមើលឃើញការណ៍នេះកាន់តែច្បាស់ កាលខ្ញុំនៅជាប៊ីស្សពក្មេងមួយរូប ពីមូលហេតុដែលព្រះអម្ចាស់ ចង់ឱ្យយើងពង្រឹងកូនចៅរបស់យើង នៅពេលពួកគេនៅក្មេង និងសង្គ្រោះពួកគេឱ្យបានឆាប់។ ខ្ញុំនឹងនិយាយប្រាប់អ្នកនូវរឿងមួយ អំពីបុរសវ័យក្មេងម្នាក់ដែលតំណាងឱ្យមនុស្សជាច្រើន ដែលខ្ញុំព្យាយាមជួយជាច្រើនឆ្នាំកន្លងមកនេះ។

នាងអង្គុយទល់មុខខ្ញុំក្នុងការិយាល័យរបស់ប៊ីស្សព។ នាងរៀបរាប់ប្រាប់ខ្ញុំ អំពីដំណើរជីវិតរបស់នាង។ នាងបានទទួល ពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់ជាសមាជិកនៃសាសនាចក្រ នៅពេលនាងមានអាយុប្រាំបីឆ្នាំ។  នាងមិនបានហូរ ទឹកភ្នែកទេពេលដែលនាងរៀបរាប់ អំពីរយៈពេលជាងម្ភៃឆ្នាំកន្លងមកនេះ ប៉ុន្តែសម្លេងរបស់នាងពោរពេញទៅដោយភាពក្រៀមក្រំ។ នាងបាននិយាយថា ផ្លូវដែលឆ្ពោះទៅរកអំពើបាបបានចាប់ផ្ដើម ពេលដែលនាងជ្រើសរើសសេពគប់ ជាមួយមនុស្សដែលនាងគិតថា ជាមនុស្សដែលមានភាពភ្ញាក់ផ្អើល។ ដំបូងនាងបានចាប់ផ្ដើមបំពានទៅលើបញ្ញត្តិដែល មើលទៅហាក់បីដូចជាមិនសូវសំខាន់។

ដំបូងនាងខ្វល់ខ្វាយបន្តិចបន្តួច ហើយមានអារម្មណ៍ថាខុសតិចតួច។ ប៉ុន្តែការសេពគប់ជាមួយមិត្តទាំងឡាយផ្ដល់នូវអារម្មណ៍ថ្មីដល់នាង ដោយចាប់ផ្ដើមមានការចូលចិត្ត ដូច្នេះហើយឱកាសនៃការតាំងចិត្តដើម្បីធ្វើការប្រែចិត្តហាក់បីដូចជាកាន់តែតិច និងមិនសូវសំខាន់។ បទបញ្ញត្តិសំខាន់ៗដែលនាងបំពានហាក់បីដូចជាកាន់តែកើនឡើង សុបិននៃការរីករាយជាមួយគេហដ្ឋានសួគ៌ាហាក់បីដូចជារលាយសាបសូន្យ។

នាងអង្គុយទល់មុខខ្ញុំ នៅក្នុងស្ថានភាពមួយកំសត់ណាស់។ នាងចង់ឱ្យខ្ញុំសង្គ្រោះនាងពីអង្គប់នៃអំពើបាបដែលនាងមានអារម្មណ៍ថាជាបន្ទុកមួយសំរាប់នាង។ ប៉ុន្តែមធ្យោបាយតែមួយគត់ដើម្បីងើបចេញពីរឿងនេះសំរាប់នាងគឺត្រូវអនុវត្តសេចក្ដីជំនឿលើព្រះយេស៊ូវ គ្រីស្ទ ត្រូវតែមានចិត្តសង្រេក ដើម្បីប្រែចិត្ត ដូច្នេះទើប

អាចជ្រះស្អាត មានការផ្លាស់ប្ដូ និងមានភាពរឹងមាំតាមរយៈដង្វាយធួនរបស់ព្រះអម្ចាស់។ ខ្ញុំបានថ្លែងទីបន្ទាល់ដល់នាងថា អ្វីគ្រប់យ៉ាង អាចទៅរួច។ វាអាចទៅរួច ប៉ុន្តែវាមានការពិបាក ជាងការអនុវត្តន៍សេចក្តីជំនឿតាំងពីនៅវ័យក្មេងក្នុងជីវិតរបស់នាង នៅក្នុងដំណើរទៅកាន់គេហដ្ឋានរបស់ព្រះ និងនៅពេលដែលនាងចាប់ផ្តើមវង្វេង កាលពីដំបូង។

ដូច្នេះហើយវិធីតែមួយគត់ដ៏ល្អបំផុតដែលយើងអាចផ្តល់ដល់កូនចៅរបស់ព្រះ គឺកសាងសេចក្តីជំនឿលើព្រះយេស៊ូវ គ្រីស្ទ និងដំណឹងល្អដែលបានស្តារឡើងវិញរបស់ទ្រង់ កាលពីពួកគេនៅក្មេង។ ហើយបន្ទាប់មកយើងត្រូវជួយដុតបំភ្លឺ សេចក្តីជំនឿនោះឱ្យបានឆាប់ មុនពេលវាត្រូវបាត់បង់ ពេលដែលពួកគេវង្វេងចេញពីផ្លូវនោះ។

ដូច្នេះ អ្នក និងខ្ញុំត្រូវបានរំពឹងទុកឱ្យចាប់យកឱកាសនៅជិតៗនេះ ដើម្បីជួយអ្នកធ្វើដំណើរក្នុងចំណោមកូនចៅរបស់ព្រះ។ ព្រះអង្គសង្គ្រោះបានប្រាប់យើងពីមូលហេតុនោះ ហេតុអ្វីយើងត្រូវធ្វើដូច្នេះ នៅពេលទ្រង់ពិពណ៌នាអំពីគ្រោះថ្នាក់ ចំពោះដំណើរត្រឡប់ទៅកាន់គេហដ្ឋានវិញ ចំពោះកូនចៅខាងវិញ្ញាណទាំងអស់របស់ព្រះនៅក្នុងអ័ព្ទនៃអំពើបាប និងនៅក្នុងអ្វីដែលសាតាំងបង្កើតឡើង៖

«ចូរឱ្យទៅតាមទ្វារចង្អៀត ត្បិតទ្វារដែលនាំទៅឯសេចក្តីបំផ្លិចបំផ្លាញ នោះធំហើយទូលាយផង ក៏មានមនុស្សជាច្រើនដែលចូលតាមទ្វារនោះ។ តែផ្លូវដែលនាំទៅឯជីវិត នោះតូចហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ»។ 1

ដោយមើលឃើញពីតំរូវការរបស់កូនចៅទ្រង់ ព្រះវរបិតាសួគ៌ជាទីស្រឡាញ់បានផ្តល់នូវសេចក្តីណែនាំ និងជួយសង្គ្រោះពួកគេតាមផ្លូវរបស់ពួកគេ។ ទ្រង់បានបញ្ជូនព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវ គ្រីស្ទ ឱ្យអាចធ្វើដំណើរនៅតាមផ្លូវដែលមានសុវត្ថិភាព និងអាចមើលឃើញ។ ទ្រង់បានហៅព្យាការីរបស់ទ្រង់នៅក្នុងជំនាន់នេះ គឺប្រធានថូម៉ាស អេស ម៉នសុន។ តាំងពីវ័យក្មេងមកម្ល៉េះ ប្រធាន ម៉នសុន មិនត្រឹមតែបានបង្រៀនឱ្យនៅលើផ្លូវនោះប៉ុណ្ណោះទេ ប៉ុន្តែក៏បានបង្រៀនឱ្យជួយអ្នកដែលស្ថិតក្នុងទុក្ខព្រួយផងដែរ។ ព្រះវរបិតាសួគ៌បានដាក់យើងនៅក្នុងស្ថានភាពខុសៗគ្នាដើម្បីជួយពង្រឹង ហើយនៅក្នុងពេលដែលចាំបាច់យើងអាចដឹកនាំអ្នកដំណើរទាំងនោះទៅរកសុវត្ថិភាពផងដែរ។ ការចាត់តាំងដ៏សំខាន់ និងមានអំណាចជាងគេគឺ នៅក្នុងក្រុមគ្រួសាររបស់យើង។ គ្រួសារសំខាន់ណាស់ ព្រោះគ្រួសារមានឱកាសចាប់ផ្តើមជីវិតកុមារឱ្យឈានជើងយ៉ាង រឹងមាំ នៅលើផ្លូវត្រឡប់ទៅគេហដ្ឋានសួគ៌វិញ។ ឪពុកម្តាយ បងប្អូនប្រុសស្រី លោកយាយលោកតា ពូ និងមីង គឺជាអ្នកណែនាំ និងអ្នកសង្គ្រោះដ៏មានអំណាច និងមានសុវត្ថិភាពដោយចំណងនៃសេចក្តីស្រឡាញ់ពីធម្មជាតិ របស់គ្រួសារ។

គ្រួសារមានអត្ថប្រយោជន៍ណាស់នៅក្នុងអាយុប្រាំបីឆ្នាំដំបូងនៃជីវិតរបស់កុមារ។ នៅក្នុងឆ្នាំដែលមាន

ការគាំពារនោះ ដោយដង្វាយធួនរបស់ព្រះយេស៊ូវ គ្រីស្ទ សាតាំងបានប្រើអំព្ទ នៃសេចក្តីងងឹតកំបាំងផ្លូវ បិទទ្វារត្រឡប់ទៅកាន់គេហដ្ឋាន សួគ៌វិញ។ នៅក្នុងឆ្នាំដ៏មានតម្លៃទាំងនោះ ព្រះអម្ចាស់បានជួយក្រុមគ្រួសារតាមរយៈការហៅអ្នកធ្វើការថ្នាក់កុមារ ដើម្បីជួយពង្រឹងកុមារខាងវិញ្ញាណ។ ទ្រង់ក៏បានផ្តល់អ្នកកាន់បព្វជិតភាពអើរ៉ុនដើម្បីធ្វើពិធីសាក្រាម៉ង់។ នៅក្នុងពិធី អធិស្ឋានសាក្រាម៉ង់ កុមារបានឮសេចក្តីសន្យាថាពួកគេអាចមានព្រះវិញ្ញាណនៃព្រះ ប្រសិនបើពួកគេគោរពតាមបញ្ញត្តិរបស់ព្រះ។ ជាលទ្ធផល ពួកគេត្រូវបានការពារទប់ទល់នឹងការល្បួងនៅពេលវាកើតមាន ហើយបន្ទាប់មក នាពេលអនាគត ពួកគេនឹងទៅសង្គ្រោះអ្នកផ្សេងទៀត។

ប៊ីស្សពភាគច្រើននៅក្នុងសាសនាចក្របានទទួលនូវការបំផុសគំនិត ដើម្បីហៅមនុស្សដែលរឹងមាំជាងគេម្នាក់នៅក្នុងវួដ ដើម្បីបំរើកុមារនៅក្នុងថ្នាក់កុមារ។ ពួកគេដឹងថាប្រសិនបើកុមារម្នាក់រឹងមាំ ដោយសារសេចក្តីជំនឿ និងទីបន្ទាល់  នោះពួកគេនឹងត្រូវការការជួយឱ្យរួចពីគ្រោះថ្នាក់កាន់តែតិចក្នុងវ័យជំទង់របស់ពួកគេ។ ពួកគេដឹងថាគ្រឹះ ដ៏រឹងមាំខាងវិញ្ញាណ អាចធ្វើឱ្យមានភាពខុសគ្នាអស់មួយជីវិត។

យើងទាំងអស់គ្នាអាចជួយ លោកយាយលោកតា និងសមាជិកគ្រប់រូប ដែលស្គាល់កុមារទាំងអស់សុទ្ធតែអាច ជួយដល់ពួកគេបាន។ វាមិនចាំបាច់ត្រូវការការហៅជាផ្លូវការនៅក្នុងថ្នាក់កុមារនោះទេ។ ឬចាំបាច់កំណត់ថាអាយុប៉ុណ្ណា នោះទេ។ ស្ត្រីម្នាក់ ជាមនុស្សក្មេងជាគេបំផុតដែលត្រូវបានហៅឱ្យធ្វើជាគណៈកម្មការថ្នាក់កុមារទូទៅ ដែលបានជួយបង្កើតបាវចនា ជ.រ.ត (ជ្រើសរើសផ្លូវត្រូវ)។

នាងមិនដែលនឿយហត់ក្នុងការបំរើដល់កុមារទេ។ នាងបង្រៀន ដល់កុមារក្នុងវួដរបស់នាង ដែលជាការស្នើសុំរបស់នាងផ្ទាល់រហូតដល់នាងមានអាយុជិត 90 ឆ្នាំ។ កុមារតូចៗអាចទទួលអារម្មណ៍ថា នាងមានសេចក្តីស្រឡាញ់ចំពោះពួកគេ។ ពួកគេបានមើលឃើញគំរូរបស់នាង។ ពួកគេបានរៀនគោលលទ្ធិដ៏សាមញ្ញ នៃដំណឹងល្អ នៃព្រះយេស៊ូវ គ្រីស្ទ។ រួមសេចក្តីមក ពីព្រោះគំរូរបស់នាង ពួកគេបានរៀនស្គាល់ពីអារម្មណ៍ និងស្គាល់ព្រះវិញ្ញាណបរិសុទ្ធ។ នៅពេលដែលពួកគេទទួលអារម្មណ៍ដូច្នេះ នោះពួកគេចាប់ផ្តើមទទួលនូវសេចក្តីជំនឿដែលពួកគេត្រូវការ ដើម្បីតទល់នឹងការល្បួង។ នោះពួកគេត្រូវការជំនួយសង្គ្រោះកាន់តែតិច ហើយពួកគេបានត្រៀមខ្លួនដើម្បីទៅសង្គ្រោះអ្នកដទៃ។

ខ្ញុំបានរៀនអំពីអំណាចនៃសេចក្តីជំនឿដ៏សាមញ្ញនៅក្នុងការអធិស្ឋាន និងព្រះវិញ្ញាណបរិសុទ្ធ នៅពេលកូនរបស់យើងនៅតូចៗ។ កូនប្រុសច្បងរបស់យើងមិនទាន់បានទទួលបុណ្យជ្រមុជទឹកនៅឡើយទេ។ ឪពុកម្តាយរបស់គាត់ គ្រូថ្នាក់កុមារ និងអ្នកដឹកនាំបព្វជិតភាព បានព្យាយាមជួយឱ្យគាត់ទទួលអារម្មណ៍ និងស្គាល់ព្រះវិញ្ញាណ ហើយដឹងអំពីរបៀបដើម្បីទទួលជំនួយពីទ្រង់។

រសៀលថ្ងៃមួយ ភរិយារបស់ខ្ញុំបានជូនគាត់ទៅផ្ទះស្ត្រីម្នាក់ ដែលបានបង្រៀនគាត់ឱ្យចេះអាន។ គម្រោង

របស់ខ្ញុំគឺត្រូវទៅទទួលគាត់ តាមផ្លូវដែលខ្ញុំត្រឡប់មកពីធ្វើការវិញ។

មេរៀនរបស់គាត់បានបញ្ចប់មុនពេលដែលយើងរំពឹងទុក។ គាត់មានទំនុកចិត្តថាគាត់ស្គាល់ផ្លូវទៅផ្ទះ។ ដូច្នេះហើយគាត់បានចាប់ផ្ដើមដើរទៅ។ ក្រោយមកគាត់និយាយថាគាត់ពិតជាមានទំនុកចិត្តខ្លាំងណាស់ ហើយពេញចិត្តនឹងគំនិតមួយគឺការធ្វើដំណើរតែម្នាក់ឯង។ បន្ទាប់ពីគាត់ធ្វើដំណើរប្រហែលជាជិតមួយគីឡូម៉ែត្រ មេឃចាប់ផ្ដើមងងឹត។ គាត់ចាប់ផ្ដើមមានអារម្មណ៍ថាគាត់នៅឆ្ងាយពីផ្ទះណាស់។

គាត់នៅចាំថា ពន្លឺភ្លើងឡានដែលបើកកាត់គាត់នោះ មើលមិនច្បាស់ដោយសារទឹកភ្នែករបស់គាត់។ គាត់មានអារម្មណ៍ ដូចជាកូនក្មេងតូចម្នាក់ គឺមិនមែនជាក្មេងប្រុសដែលមានទំនុកចិត្ត ថាអាចចាប់ផ្ដើមដើរទៅផ្ទះតែម្នាក់ឯងបាននោះទេ។ គាត់ចាប់ផ្ដើមដឹងថាគាត់ត្រូវការជំនួយ។ ពេលនោះមានអ្វីមួយបានផុសឡើងក្នុងគំនិតរបស់គាត់។ គាត់ដឹងថាគាត់ ត្រូវការអធិស្ឋាន។ ហើយគាត់បានចុះពីលើថ្នល់ហើយដើរសំដៅទៅរកដើមឈើដែលគាត់មើលឃើញតិចៗ នៅពេលមេឃងងឹត។ គាត់បានរកកន្លែងលុតជង្គង់ចុះអធិស្ឋាន។

តាមរយៈគុមគម្ពោចនោះគាត់អាចឮសម្លេងនិយាយមកកាន់គាត់។ មនុស្សវ័យក្មេងពីរនាក់បានឮគាត់កំពុងយំ។ ពេលពួកគេដើរមកជិត ពួកគេនិយាយថា៖ «តើយើងអាចជួយអ្នកបានទេ?» គាត់និយាយប្រាប់ពួកគេទាំងទឹកភ្នែកថា គាត់វង្វេងផ្លូវ ហើយគាត់ចង់ត្រឡប់ទៅផ្ទះវិញ។ តើគាត់ចាំលេខទូរស័ព្ទ ឬអាស័យដ្ឋានផ្ទះឬទេ។ គាត់មិនចាំទេ។ ពួកគេបានសួរថាតើគាត់ស្គាល់ឈ្មោះរបស់គាត់ទេ ពួកគេបាននាំគាត់ទៅជិតកន្លែងដែលគាត់រស់នៅ។ ពួកគេបានរកឈ្មោះត្រកូលនៅក្នុងសៀវភៅទូរស័ព្ទ។

នៅពេលខ្ញុំទទួលទូរស័ព្ទហើយ ខ្ញុំប្រញាប់ប្រញាល់ ទៅជួបអ្នកសង្គ្រោះ ដោយមានអំណរគុណចំពោះព្រះដែលបានបញ្ជូនមនុស្សល្អនៅតាមផ្លូវត្រឡប់ទៅផ្ទះវិញរបស់គាត់។ ហើយខ្ញុំតែងតែមានអំណរគុណ ដែលគាត់ត្រូវបានបង្រៀនឱ្យអធិស្ឋានជាមួយសេចក្ដីជំនឿ ហើយជំនួយនោះបានកើតមាននៅពេលគាត់វង្វេងផ្លូវ។ សេចក្ដីជំនឿនោះបានដឹកនាំគាត់ទៅរកសុវត្ថិភាព ហើយបានធ្វើឱ្យគាត់ក្លាយទៅជាអ្នកជួយសង្គ្រោះវិញជាច្រើនដងរាប់មិនអស់។

ព្រះអម្ចាស់បានរៀបចំគំរូសង្គ្រោះ និងអ្នកជួយសង្គ្រោះនៅក្នុងនគររបស់ទ្រង់។ ព្រះបញ្ញារបស់ទ្រង់ គឺព្រះអម្ចាស់បានបំផុសគំនិត អ្នកបំរើរបស់ទ្រង់នូវមធ្យោបាយដ៏មានអំណាចដើម្បីជួយពង្រឹងយើង ទ្រង់បានចាត់តាំងអ្នកជួយសង្គ្រោះដ៏ល្អបំផុត នៅពេលយើងឆ្លងកាត់ជីវិតជាយុវវ័យ។

អ្នកបានដឹងអំពីកម្មវិធីពីរដ៏មានអំណាចដែលបានផ្ដល់ឱ្យដោយព្រះអម្ចាស់។ មួយសំរាប់យុវនារី គឺត្រូវបានហៅថា «ការពង្រីកខ្លួនរបស់យុវនារី» មួយទៀតសំរាប់អ្នកកាន់បព្វជិតភាពអើរ៉ុន គឺត្រូវបានហៅថា «កាតព្វកិច្ចចំពោះព្រះ» យើងសូមលើកទឹកចិត្តដល់យុវជនវ័យក្មេង នៃជំនាន់ដែលកំពុងពេញវ័យសូម

មើលឃើញពីសក្តានុពលរបស់ពួកគេ ក្នុងការកសាងពង្រឹងខាងវិញ្ញាណដ៏អស្ចារ្យ។ ហើយយើងសូមអង្វរដល់អស់អ្នកដែលថែទាំយុវជនវ័យក្មេងទាំងនោះ សូមចិញ្ចឹមពួកគេទៅតាមអ្វីដែលព្រះអម្ចាស់ចង់ឱ្យយើងធ្វើ ដើម្បីជួយពួកគេ។ ហើយដោយសារអនាគត របស់សាសនាចក្រពឹងផ្អែកលើពួកគេ ដូច្នេះយើងទាំងអស់គ្នាត្រូវតែយកចិត្តទុកដាក់។

កម្មវិធីទាំងពីរបានកែលំអរ ប៉ុន្តែគោលបំណងរបស់វាបន្តដោយគ្មានការប្រែប្រួល។ ប្រធាន ម៉នសុន  បានចាត់ទុករបៀបនេះ៖ យើងត្រូវតែ «រៀននូវអ្វីដែលយើងគួររៀន ធ្វើនូវអ្វីដែលយើងគួរធ្វើ ហើយទៅកន្លែងណាដែលយើងគួរទៅ»។ 2

កូនសៀវភៅការពង្រីកខ្លួនរបស់យុវនារី បានបង្ហាញពីគោលបំណងយ៉ាងច្បាស់លាស់ចំពោះពួកគេ៖

«កម្មវិធីការពង្រីកខ្លួនរបស់យុវនារី បានប្រើនូវតម្លៃទាំងប្រាំបីរបស់យុវនារី ដើម្បីជួយអ្នកឱ្យយល់កាន់តែច្បាស់ថាតើអ្នកជានរណា ហេតុអ្វីអ្នកមករស់នៅលើផែនដី ហើយអ្នកគួរតែធ្វើអ្វីក្នុងនាមជាបុត្រីរបស់ព្រះ ដើម្បីរៀបចំខ្លួនសំរាប់ថ្ងៃដែលអ្នកត្រូវទៅព្រះវិហារបរិសុទ្ធ ដើម្បីធ្វើសេចក្តីសញ្ញាពិសិដ្ឋ»។ 3

សៀវភៅនេះបន្តនិយាយទៀតថា យុវនារីនឹង «ធ្វើការតាំងចិត្ត អនុវត្តវា ហើយរាយការណ៍អំពីការរីកចំរើនរបស់អ្នក ទៅឪពុកម្តាយ ឬអ្នកដឹកនាំ» វាក៏បានសន្យាដែរថា «គំរូទាំងឡាយដែលអ្នកស្ថាបនាឡើង នៅពេលអ្នកធ្វើការក្នុងសៀវភៅការរីកចំរើនផ្ទាល់ខ្លួន--- ដូចជាការអធិស្ឋាន ការសិក្សាព្រះគម្ពីរ ការបំរើ និងការរក្សាកំណត់ហេតុ--- នឹងក្លាយជាទម្លាប់ប្រចាំថ្ងៃផ្ទាល់ខ្លួន។ ទម្លាប់ទាំងនេះ នឹងពង្រឹងដល់ទីបន្ទាល់របស់អ្នក ហើយជួយអ្នកឱ្យរៀន និងរីកចំរើនអស់មួយជីវិតរបស់អ្នក»។ 4

កម្មវិធីកាតព្វកិច្ចចំពោះព្រះ សំរាប់យុវជននៅក្នុងបព្វជិតភាពអើរ៉ុន បានជួយពង្រឹង និងមានការផ្តោតយកចិត្តទុកដាក់។ វាមាននៅក្នុងកូនសៀវភៅធម្មតាមួយ សំរាប់មុខតំណែងទាំងបីនៃបព្វជិតភាពអើរ៉ុន។ យុវជននឹងអ្នកដឹកនាំរបស់ពួកគេ នឹងទទួលបានកូនសៀវភៅថ្មីនេះម្នាក់មួយច្បាប់។ វាគឺជាឧបករណ៍ដ៏មានអំណាច។

វានឹងជួយពង្រឹងដល់ទីបន្ទាល់របស់យុវជន និងទំនាក់ទំនងពួកគេជាមួយព្រះ។ វានឹងជួយពួកគេរៀន ហើយចង់បំពេញកាតព្វកិច្ចរបស់ពួកគេ។ វានឹងជួយពង្រឹងទំនាក់ទំនងពួកគេជាមួយឪពុកម្តាយ ក្នុងចំណោមសមាជិកក្រុម និងរវាងយុវជន និងអ្នកដឹកនាំរបស់ពួកគេ។

កម្មវិធីទាំងពីរបានដាក់ការទទួលខុសត្រូវយ៉ាងធំ ក្នុងកិច្ចខិតខំរបស់មនុស្សវ័យក្មេងផ្ទាល់។ ពួកគេត្រូវបានអញ្ជើញឱ្យរៀន និងធ្វើនូវអ្វីដែលនឹងមានការពិបាកសំរាប់មនុស្សគ្រប់រូប។ ពេលខ្ញុំគិតអំពីយុវវ័យរបស់ខ្ញុំ

ផ្ទាល់ ខ្ញុំមិនចាំអំពីអ្វីដែលជាឧបសគ្គនោះទេ។ មែនហើយ ម្ដងម្កាល ខ្ញុំត្រូវបានអញ្ជើញឱ្យសំរេចនូវការពិបាកៗ ប៉ុន្តែយូរៗម្ដងប៉ុណ្ណោះ។ កម្មវិធីនេះរំពឹងទុកឱ្យមានការធ្វើជាប់ជានិច្ច ត្រូវខិតខំឱ្យខ្លាំង និងបង្កើននូវការរៀនសូត្រ និងបទពិសោធន៍ខាងវិញ្ញាណរាប់ឆ្នាំ។

នៅពេលខ្ញុំគិតអំពីវា ខ្ញុំដឹងថាមាតិការនៃកូនសៀវភៅនេះ គឺតំណាងឱ្យសាច់ឈាម នៃការទុកព្រះទ័យរបស់ព្រះអម្ចាស់ ចំពោះជំនាន់ដែលកំពុងពេញវ័យ និងចំពោះយើងទាំងអស់គ្នាដែលស្រឡាញ់ពួកគេ។ ហើយខ្ញុំបានមើលឃើញភស្តុតាងថា ការទុកព្រះទ័យនោះគឺបានរៀបចំយ៉ាងល្អ។

នៅក្នុងការទៅសួរសុខទុក្ខពួកគេ ខ្ញុំបានមើលឃើញទង្វើរបស់ក្រុមបព្វជិតភាពអើរ៉ុន។ ខ្ញុំបានមើលឃើញយុវជនធ្វើ តាមគំរូនៃការរៀនសូត្រ ដាក់ផែនការធ្វើនូវអ្វីដែលព្រះចង់ឱ្យពួកគេធ្វើ ហើយបន្ទាប់មកធ្វើនូវអ្វីដែលពួកគេប្ដេជ្ញា ថាត្រូវធ្វើ ហើយចែកចាយជាមួយអ្នកដទៃនូវការផ្លាស់ប្ដូរខាងវិញ្ញាណរបស់គេ។ ហើយនៅពេលដែលខ្ញុំមើល និងស្ដាប់ វាកាន់តែធ្វើឱ្យខ្ញុំមើលឃើញច្បាស់ថា ឪពុកម្ដាយ អ្នកដឹកនាំ មិត្តភក្តិ និងសូម្បីតែអ្នកជិតខាងក្នុងក្រុមជុំនុំ ត្រូវបានដក់ជាប់ដោយព្រះវិញ្ញាណ នៅពេលពួកគេបានឮអំពីទីបន្ទាល់របស់យុវវ័យអំពីរបៀបដែលពួកគេត្រូវបានពង្រឹង។ យុវវ័យត្រូវបានលើកឡើង នៅពេលពួកគេថ្លែងទីបន្ទាល់ ក៏ដូចគ្នាជាមួយនឹងអ្នក ដែលព្យាយាមជួយបីបាច់ពួកគេផងដែរ។

កម្មវិធីយុវនារីមានគំរូដ៏មានអំណាចដូចគ្នា ដើម្បីអភិវឌ្ឍកម្លាំងខាងវិញ្ញាណនៅក្នុងយុវនារី ហើយផ្ដល់ឱកាសដល់យើងដើម្បីជួយ។ សៀវភៅការអភិវឌ្ឍន៍ខ្លួនសំរាប់យុវនារី ជួយយុវនារីឱ្យទទួលពិធីការនៃព្រះវិហារបរិសុទ្ធ។ វាបានជួយតាមរយៈគំរូរបស់ម្ដាយ លោកយាយ និងស្ត្រីសុចរិតគ្រប់រូបដែលនៅជុំវិញពួកគេនៅក្នុងសាសនាចក្រ។ ខ្ញុំបានមើលឃើញអំពីរបៀបដែលឪពុកម្ដាយជួយកូនស្រីសម្រេចបាននូវគោលដៅ និងសុបិនរបស់នាង តាមរយៈការកត់សំគាល់ និងចូលរួមចំណែកនូវរាល់គ្រប់កិច្ចការល្អដែលនាងបានធ្វើ។

ទើបតែប៉ុន្មានថ្ងៃកន្លងទៅប៉ុណ្ណោះ ខ្ញុំបានមើលម្ដាយម្នាក់ឈរជាមួយកូនស្រីរបស់នាងនៅពេលពួកគេទទួល រង្វាន់ដែលពួកគេបានក្លាយជាគំរូ ដ៏លេចធ្លោរក្នុងភាពជាស្ត្រី។ ហើយពួកគេបានចែកចាយជាមួយខ្ញុំតើវាមានន័យយ៉ាងណាចំពោះពួកគេ នោះខ្ញុំបានទទួលអារម្មណ៍ដោយមានការអនុញ្ញាតពីព្រះអម្ចាស់ ហើយព្រមទាំងលើកទឹកចិត្តដល់យើងទាំងអស់គ្នា។

សូមផ្ដល់ជំនួយដែលយើងអាចធ្វើបានដល់មនុស្សវ័យក្មេងទាំងនេះ នោះអ្វីដែលអស្ចារ្យនឹងដឹកនាំពួកគេឱ្យទទួលនូវអារម្មណ៍ដែលមានទំនុកចិត្តថាពួកគេនៅតាមផ្លូវត្រឡប់ទៅកាន់គេហដ្ឋានព្រះ ហើយពួកគេអាចធ្វើបាន។ ហើយយើងធ្វើនូវអ្វីដែលប្រសើរបំផុតដើម្បីទៅជាមួយពួកគេ។ ពីព្រោះនៅតាមផ្លូវមានគ្រឡុក ហើយពេលខ្លះមានថ្ម នៅពេលខ្លះពួកគេនឹងមានអារម្មណ៍បាក់ទឹកចិត្ត និងអាប់អួរ។ នៅពេលខ្លះ

ពួកគេនឹងច្របូកច្របល់ អំពីជោគវាសនារបស់ពួកគេ ហើយងឿងឆ្ងល់ បន្ទាប់ពីការស្វែងរកគោលដៅដែលមិនសូវសំខាន់ចំពោះភាពអស់កល្បរបស់ពួកគេ។ កម្មវិធីដែលមានការបំផុសនេះយ៉ាងហោចណាស់ក៏ធ្វើឱ្យមានចំណាប់អារម្មណ៍ ពីព្រោះវានឹងដឹកនាំជំនាន់ដែលកំពុងពេញវ័យឱ្យអញ្ជើញ និងទទួលភាពជាដៃគូពីព្រះវិញ្ញាណបរិសុទ្ធ។

ដំបូន្មានដ៏ល្អបំផុតសំរាប់យើងដែលត្រូវផ្ដល់ឱ្យជំនាន់ដែលកំពុងពេញវ័យគឺថា ពួកគេអាចត្រឡប់ទៅកាន់ព្រះវរបិតាសួគ៌វិញមានតែតាមរយៈការដឹកនាំ និងការកែតំរូវពីព្រះវិញ្ញាណនៃព្រះប៉ុណ្ណោះ។ ដូច្នេះហើយ បើសិនជាយើងឈ្លាសវៃ យើងនឹងមានសេចក្ដីក្លាហាន ការសរសើរ និងយកគំរូតាមគ្រប់យ៉ាងដែលអញ្ជើញភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ។ នៅពេលពួកគេចែកចាយនូវអ្វីដែលពួកគេកំពុងធ្វើ និងអារម្មណ៍ដែលពួកគេមាន នោះយើងក៏ត្រូវតែមានភាពសក្ដិសមដើម្បីមានព្រះវិញ្ញាណបរិសុទ្ធផងដែរ។ បន្ទាប់មកយើងនឹងទទួលអារម្មណ៍ដោយក្ដីកោតសសើរ និងស្នាមញញឹម នៃការស្រុះស្រួលជាមួយព្រះ។ ហើយបើសិនជាយើងមានអារម្មណ៍ថាត្រូវផ្ដល់ដំបូន្មានដែលត្រឹមត្រូវ នោះពួកគេនឹងទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់យើង និងរបស់ព្រះនៅក្នុងនោះ គឺមិនមែនជាការស្ដីបន្ទោស ហើយបដិសេធ ដែលអាចបើកដៃឱ្យសាតាំងដឹកនាំអនាគតពួកគេនោះទេ។

គំរូដែលពួកគេត្រូវការពីយើងបំផុតគឺ ធ្វើនូវអ្វីដែលពួកគេត្រូវធ្វើ។ យើងត្រូវអធិស្ឋានសុំអំណោយទាននៃព្រះវិញ្ញាណ។ យើងត្រូវធ្វើការពិចារណានៅក្នុងព្រះគម្ពីរ និងពាក្យពេចន៍របស់ព្យាការីដែលនៅរស់។ យើងត្រូវរៀបចំផែនការ ដែលមិនត្រឹមតែជាបំណងប្រាថ្នាប៉ុណ្ណោះទេ ប៉ុន្តែគឺជាសេចក្ដីសញ្ញា។ បន្ទាប់មកយើងត្រូវរក្សាសេចក្ដីសន្យារបស់យើងចំពោះព្រះ។ ហើយយើងត្រូវលើកអ្នកដទៃឡើងតាមរយៈការចែកចាយពរជ័យនៃដង្វាយធួនដែលកើតមានចំពោះជីវិតរបស់យើង។

ហើយយើងត្រូវយកមកប្រើប្រាស់ក្នុងជីវិតរបស់យើងផ្ទាល់ ហើយត្រូវខ្ជាប់ខ្ជួន និងបន្តមានភាពស្មោះត្រង់ដែលព្រះអម្ចាស់រំពឹងចង់បានពីពួកគេ។ ហើយពេលយើងធ្វើដូច្នេះ យើងនឹងជួយពួកគេឱ្យទទួលអារម្មណ៍ពីព្រះវិញ្ញាណនិងការអះអាងថាប្រសិនបើពួកគេនឹងតទល់ជាមួយវានោះពួកគេនឹងឮព្រះបន្ទូលពីព្រះអង្គសង្គ្រោះ និងព្រះវរបិតាសួគ៌ជាទីស្រឡាញ់ថា៖ «...ប្រពៃហើយបាវល្អស្មោះត្រង់អើយ ឯងមានចិត្តស្មោះនឹងត្រួតរបស់បន្តិចនេះ ដូច្នេះអញនឹងតាំងឱ្យឯងត្រួតលើរបស់ជាច្រើនទៀត ចូរឱ្យឯងប្រកបដោយសេចក្ដីអំណររបស់ចៅហ្វាយឯងចុះ»។5 ហើយយើងដែលជាអ្នកបានជួយពួកគេ នឹងឮពាក្យពេចន៍ទាំងនោះដោយក្ដីអំណរ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា ព្រះអម្ចាស់ស្រឡាញ់អ្នក និងកូនចៅគ្រប់រូបរបស់ព្រះ។ នេះគឺជានគររបស់ទ្រង់ដែលបានស្ដារឡើងដោយកូនសោរបព្វជិតភាព តាមរយៈព្យាការី យ៉ូសែប ស្ម៊ីធ។  ថូម៉ាស អេស ម៉នសុនគឺជាព្យាការីរបស់ព្រះអម្ចាស់នាពេលបច្ចុប្បន្ននេះ។ ខ្ញុំសូមសន្យានឹងអ្នករាល់គ្នាម្នាក់ៗថា នៅពេលអ្នកធ្វើ

តាមការណែនាំដែលមានការបំផុសគំនិតនៅក្នុងសាសនាចក្រពិតនៃព្រះយេស៊ូវគ្រីស្ទ អំពីពួកយុវវ័យនោះ យើងដែលជាអ្នកជួយ និងស្រឡាញ់ពួកគេ អាចបញ្ជូនពួកគេទៅគេហដ្ឋានព្រះវរបិតាសួគ៌ និងព្រះអង្គសង្គ្រោះដោយសុវត្ថិភាព ដើម្បីរស់នៅជាមួយក្រុមគ្រួសារ និងមានក្ដីអំណរជារៀងរហូត។ នៅក្នុងព្រះនាមព្រះយេស៊ូវ គ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. នីហ្វៃទី 3 14:13--14។
2. សូមមើល Thomas S. Monson សន្និសីទទូទៅ ខែ តុលា ឆ្នាំ 2008។
3. កូនសៀវភៅ ការពង្រីកខ្លួនរបស់យុវនារី «ការឈរជាសាក្សីរបស់ព្រះ» ទំព័រ 6។
4. កូនសៀវភៅ ការពង្រីកខ្លួនរបស់យុវនារី «ការឈរជាសាក្សីរបស់ព្រះ» ទំព័រ 6 ។
5. ម៉ាថាយ 25:21។